**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានការសោកស្តាយយ៉ាងខ្លាំង និងសូមបដិសេធចំពោះរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ដែលបានចេញផ្សាយ កាលពីព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ នូវរបាយការណ៍គ្មានមូលដ្ឋានវិជ្ជាជីវៈច្បាស់លាស់។

បច្ចុប្បន្ន កម្ពុជាបាននឹងកំពុងសហការយ៉ាងជិតស្និទ្ធនិងប្រកបដោយតម្លាភាពនូវកម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO BFC) ដើម្បីធ្វើអធិការកិច្ចការងារ និងវាយតម្លៃលក្ខខណ្ឌការងារនៅកម្ពុជាប្រកបដោយវិជ្ជាជីវៈ បន្ថែមលើយន្តការអធិការកិច្ចលក្ខខណ្ឌការងារ សុវត្ថិភាព និងអនាម័យការងារ ដែលមានស្រាប់។ កន្លងមកក៏ដូចជាបច្ចុប្បន្ន សហគមន៍អន្តរជាតិ អ្នកបញ្ជាទិញ និងអង្គការអន្តរជាតិខាងការងារ (ILO) បានគាំទ្រ និងទទួលស្គាល់ថា លក្ខខណ្ឌការងារនៅកម្ពុជាមានភាពល្អប្រសើរ ស្របតាមបទដ្ឋានអន្តរជាតិ ព្រមទាំងបានលើកទឹកចិត្តឱ្យបណ្តាប្រទេសផ្សេងទៀតយកគំរូតាមប្រទេសកម្ពុជាក្នុងការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងយកចិត្តទុកដាក់ពង្រឹងយន្តការនិងប្រសិទ្ធភាពនៃអធិការកិច្ចការងារ និងដាក់ពិន័យដល់សហគ្រាស គ្រឹះស្ថានទាំងឡាយណាដែលបានល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ជាក់ស្តែងក្នុងឆ្នាំ២០១៤ កន្លងទៅនេះ ក្រុមអធិការកិច្ចការងារតែមួយចំនួន ៤៩ ក្រុម បានធ្វើអធិការកិច្ចការងារបានចំនួន ៧ ១៩១ លើក បានដាក់កំហិតលើសហគ្រាស គ្រឹះស្ថានចំនួន ៨០៥ និងបានផាកពិន័យសហគ្រាស គ្រឹះស្ថានចំនួន ១២៨។

ដូច្នេះ អ្វីដែលបានលើកឡើងក្នុងរបាយការណ៍របស់អង្គការនេះ គឺមិនអាចទទួលយកបានឡើយ ពីព្រោះបានរំលោភលើវិជ្ជាជីវៈរបស់ក្រសួង និងកម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា របស់អង្គការអន្តរជាតិខាងការងារ ដែលបាននិងកំពុងបំពេញការងារនេះ ប្រកបដោយវិជ្ជាជីវៈនិងប្រសិទ្ធភាព។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩